# រឿងនិទាន

## សម្រែកមិត្តកសិករ







ថ្ងៃមួយ មានបុរសម្នាក់បានចេញទៅបរបាញ់សត្វក្នុងព្រៃក្បែរភូមិ ។ ជាចៃដន្យថ្ងៃនោះមានពពួកសត្វ បក្សី ត្រី កង្កែប បានជួបប្រជុំគ្នាក្បែរមាត់ស្រះមួយ។ ឃើញដូចនោះបុរសបានលើកធ្នូរបំរុងនឹងបាញ់សត្វបក្សី ស្រាប់តែមានអរុក្ខអារក្សម្នាក់ បាននិយាយឡើងថា ឈប់ៗចូរអ្នកកុំបាញ់ ពួកគេថ្ងៃនេះពួកគេមានការប្រជុំមួយ យ៉ាងសំខាន់ ហើយរឿងនេះក៏មានទាក់ទង និងផលប្រយោជន៏អ្នកដែរ ។ ឮ ដូចនោះបុរសក៏ផ្ទៀងត្រចៀកស្តាប់ពួកសត្វចាប់ផ្តើមអង្គប្រជុំ :

- ថ្ងៃនេះពួកយើងទាំងអស់គ្នាមានការប្រជុំមួយស្តីពី (ទុក្ខវេទនាមិត្តកសិករ) ។ ប្រធានអង្គប្រជុំចាប់ផ្តើមនិយាយ :
- សូមមិត្តលើកឡើងពីបញ្ហាលំបាកនិងទុក្ខវេទនារបស់ខ្លួនដើម្បីចែករំលែកដល់មិត្តយើងទាំងអស់គ្នាស្តាប់កង្កែបលើកដៃឡើងមុនគេ:

ឱមិត្តទាំងអស់គ្នាដឹងទេសព្វថ្ងៃនេះ ពួកខ្ញុំជិតដាច់ពូជហើយ រដូវដើមឆ្នាំមកដល់ពួកយើងសប្បាយណាស់ភ្លៀងធ្លាក់មកយ៉ាងច្រើន ពួកខ្ញុំប្រុសៗ បានចេញដំណើរស្វែងរកដៃគូដើម្បីរួមមេ ត្រីបង្កើតកូនចៅឲ្យបានច្រើន តែវាស្ទើរតែគ្មានលទ្ធផលសោះ។ កំពុងតែសាសងគ្នា ស្រាប់តែពួកមនុស្សមកដល់ចាប់ពួកយើងយកទាំងគូៗ។ មិនតែប៉ុណ្ណោះពេលខ្លះពួកយើងឃើញភ្លើងពិលរបស់ពួកគេខំរត់គេចទំលាក់ខ្លួនក្នុងទឹកជ្រៅស្រាប់តែពួក គេមានឧបករណ៍មកចក់ទាញបណ្តាលឲ្យពួកយើង សន្លប់ ហើយពួកគេចាប់យកតែម្តង ។

អ្នកដឹងទេពួកខ្ញុំបានជួយចាប់សត្វល្អិត មមាចត្នោត និងសត្វល្អិតចង្រៃបំផ្លាញស្រូវ និងដំណាំ ពួកគេក្នុង ១យប់ សំរាប់គ្នាយើង ម្នាក់ បាន ពី ៥០០ ទៅ ៦០០ សត្វឯណោះ។ ពួកយើងម្នាក់អាចបង្កើតកូនបានពី ៧០០ ទៅ ៨០០ កូនក្នុង ១ ឆ្នាំ បើសិនជាទុកឲ្យយើងបង្កើតកូនហើយចាំចាប់ពួកយើងពិតជាល្អណាស់ ។ ឮដូចនោះត្រីឲ្យសញ្ញាដើម្បី បាននិយាយបន្ត: ពួកខ្ញុំក៏មិនខុសពីពួកអ្នកប៉ុន្មានទេនៅរដូវដើមឆ្នាំមានភ្លៀងមក ពួកយើងបានឡើងចេញ ពីស្រះ បឹងបួរ ត្រពាំងធំៗដើម្បីរកគូមេត្រី បង្កបង្កើតកូនចៅតែមិនដែលបានសំរេចសោះ ពេលចាប់ផ្តើមឡើងចេញត្រូវពួកមនុស្សចាប់យក មិនតែប៉ុណ្ណោះពេលខ្លះយើងបានហែលដល់ស្រែ ឬប្រលាយ នៅមានមនុស្សយកឧបករណ៍ចក់ មកទាញយក ពួក យើងទាំងគូ មានមិត្តខ្ញុំម្នាក់ត្រូវឧបករណ៍ចក់

តែសំណាងល្អ មនុស្សរកនាងមិនឃើញឡើយ នាងត្រូវរួចជីវិតតែនាងត្រូវទទួល ការរងទុក្ខមិនអាចកើតកូនបាន (អា) រហូតដល់ ៤ឆ្នាំ ។



រាល់ថ្ងៃពួកខ្ញុំជួយកំចាត់សត្វល្អិត ដូចកង្កែបដែរ ថែមទាំង ជួយជ្រួយជើងដល់ដំណាំស្រូវឲ្យស្រូវបានល្អ ក្នុងគ្នាយើងម្នាក់ អាចកំចាត់សត្វល្អិតបាន ពី ៥០០-៦០០ក្នុង ១ថ្ងៃ ។ នឹងដើរ តួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ស្បៀងដល់មនុស្ស តែ ពួកគេមិនដែលគិតដល់រឿងនេះសោះ ។

ពេលនេះដល់ពេលដែលបក្សី និយាយម្តងហើយ :




ចំណែកពួកខ្ញុំវិញក៏មិន ខុសពីអ្នកទាំងអស់គ្នាដែរ ពួកខ្ញុំត្រូវស្លាប់យ៉ាងវង្គាលដោយសារមនុស្ស ពួកគេបំពុលខ្ញុំ និងប្រើវិធីសាស្ត្របន្លំភ្នែក និងត្រចៀក ដោយពួកគេមានសម្លេងបន្លំបានប្រើលប់ធំៗដោយដាក់គ្នាយើងជាសញ្ញាឃើញ ដូចនោះគ្នាយើងចុះទាំងហ្វូង។ ច្រើនលើសលុបហើយត្រូវជាប់លបគេទាំងហ្វូង ។ អ្នកដឹងទេយើងបានជួយពួកមនុស្សក្នុងការសម្លាប់សត្វល្អិត សម្លាប់ដង្កូវ បំផ្លាញស្រូវ និងជួយច្រៀងកំដរបរិយាកាសឲ្យពីរោះរណ្តំតាមធម្មជាតិទៀតផង។ បុរសនោះបានលាន់មាត់:



ហ៊ឺគួរអាណិត ដល់សត្វទាំងអស់នោះណាស់ មិនគួរណា មនុស្សបំផ្លាញពួកសត្វទាំងនោះទេ យើងហាក់មិនបានដឹង ពីផលប្រយោជន៍ របស់មិត្តយើងសោះ ពួកគេជួយយើងច្រើន ណាស់។ បុរសបានសួរទៅកាន់អរក្សថា: តើយើងមានវិធីសាស្ត្រអ្វីខ្លះដែលអាចជួយគេបាន?

លោកអារក្ស ឆ្លើយតប: ហា.......! មិនមានអ្វីពិបាកឡើយចូរអ្នកធ្វើ តាមយើងដូចខាងក្រោម: ពេលអ្នកទៅដល់ភូមិវិញ អ្នកត្រូវផ្សព្វផ្សាយពីអ្វីដែលអ្នកបានឮ ថ្ងៃនេះឲ្យអ្នកភូមិបានដឹងបន្ទាប់មក អ្នកត្រូវរកអ្នកចាប់អារម្មណ៍ដើម្បីបង្កើតជាក្រុមមួយការពារ និងផ្សព្វផ្សាយពីការគ្រប់គ្រង ធនធានធម្មជាតិត្រូវទាក់ទងទៅអ្នកពាក់ព័ន្ធ ដូចជា ប៉ុស្តិ៍ឃុំ អង្គការពាក់ព័ន្ធ ដើម្បីចូលរួមក្នុងការគាំទ្រគម្រោងនេះ។ ចាំបាច់ត្រូវបង្កើតច្បាប់ ឬលក្ខន្តិក:ដើម្បីធ្វើការផាកពិន័យដល់អ្នកល្មើសច្បាប់។

**រៀបរៀងដោយ: ក្រុមការងារគំរោងសង្គមស៊ីវិល**
**និងទីផ្សារគាំទ្រជីវភាពអ្នកក្រីក្ររបស់អង្គការសេដាក**